# អ្នកស្រី ផ្លឹក ភីរុំ



*"ពួកគាត់គួរតែចូលរួមសួរសំណួរ បញ្ចេញមតិទៅតាមបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក វេទិកាសាធារណៈ ឬធ្វើការស្នើសុំអាជ្ញាធរឱ្យបង្រៀនអំពីច្បាប់ពាក់ព័ន្ធដែលគាត់ចង់ដឹង។"*

អ្នកស្រី ផ្លឹក ភីរុំ មានអាយុ ៣៩ ឆ្នាំ ជាជនជាតិដើមភាគតិចពូនង រស់នៅភូមិឡេកា សង្កាត់សុខដុម ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ហើយសព្វថ្ងៃនេះ អ្នកស្រីជាកសិករ និងជាអ្នកសម្របសម្រួលក្រុមជនជាតិដើមភាគតិចនៅ ខេត្តមណ្ឌលគិរីដែលមានចំនួន ៥ ស្រុក សរុប ៣៩ ភូមិ។

អ្នកស្រីបានចាប់ផ្តើមក្លាយជាអ្នកការពារសិទ្ធិជនជាតិដើមភាគតិចតាំងពីឆ្នាំ២០១០ ដោយសារអ្នកស្រីបានជួបប្រទះបញ្ហាផ្ទាល់ ពីការឈូសឆាយដីធ្លីសហគមន៍ជនជាតិដើមភាគតិចនៅក្នុងសហគមន៍របស់អ្នកស្រីពីសំណាក់ក្រុមហ៊ុនវិនិយោគមួយ ព្រមទាំងធនធានធម្មជាតិ និងវប្បធម៌របស់ជនជាតិដើមភាគតិច ទើបជំរុញឱ្យអ្នកស្រីបានចូលរួមការពារវប្បធម៌ និងធនធានធម្មជាតិរបស់សហគមន៍។

ដំបូងឡើយអ្នកស្រីបានអនុវត្តការងារជាអ្នកការពារសិទ្ធិជនជាតិភាគតិច ដោយបានជជែកជាមួយសមាជិកសហគមន៍ផ្សេងទៀតអំពីផលប៉ះពាល់ដីធ្លី ធនធានធម្មជាតិ ក៏ដូចជាវិនាសកម្មព្រៃឈើជាដើម។ បន្ទាប់មក តំណាងសហគមន៍ និងសមាជិកនៅតំបន់ផ្សេងទៀតដូចជា ប៊ូស្រា កោះញ៉ែក មនោរម្យ កែវសីមា អូរាំង បានចូលរួមធ្វើសកម្មភាពដាក់ញត្តិតស៊ូមតិរួមគ្នានៅសាលាខេត្ត និងសាលាដំបូងខេត្តមណ្ឌលគិរី ដើម្បីស្វែងរកដំណោះស្រាយជូនជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ពីក្រុមហ៊ុនដើម្បីបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ និងឈូសឆាយដីព្រៃរបស់សហគមន៍។

សមិទ្ធផលជោគជ័យដែលអ្នកស្រីទទួលបានកន្លងមកមានដូចជា ការចូលរួមទាមទារដីធ្លីពីក្រុមហ៊ុនវីឡាឌីវេឡុប់មិណ បានចំនួន២៧ហិចតាត្រឡប់មកវិញ នៅខែឧសភា ឆ្នាំ២០១៧ ហើយសម្របសម្រួលសហគមន៍ជនជាតិដើមភាគតិចឱ្យទទួលចំណេះដឹងពីវគ្គបណ្តុះបណ្តាលផ្សេងៗ មានដូចជា ច្បាប់ សិទ្ធិស្វ័យសម្រេច និងសិទ្ធិជនជាតិដើមភាគតិចជាដើម។

ក្រៅអំពីសមិទ្ធផលជោគជ័យនៅក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន អ្នកស្រីធ្លាប់ត្រូវបានគេគំរាមសម្លាប់ផងដែរ នៅពេលដែលអ្នកស្រីប្រារព្ធពិធីជនជាតិដើមភាគតិចនៅក្នុងឆ្នាំ២០១៧។ នៅក្នុងឆ្នាំ២០១៨ អ្នកស្រីក៏ត្រូវ

បានគេគំរាមជាលើកទី២ក្នុងការតស៊ូមតិបញ្ហាភ្នំដោះក្រមុំ ហើយការគំរាមសម្លាប់លើកទី៣ នៅពេលដែលអ្នកស្រីការពារដីធ្លីជនជាតិដើមភាគតិចចំនួន ៧០ ហិចតា។ នៅឆ្នាំ២០១៦ អ្នកស្រី និងសហគមន៍ដទៃទៀតត្រូវបានគេប្ដឹងពីបទបង្ករបួសស្នាម រហូតដល់ឆ្នាំ២០១៨ ទើបប៉ូលីសប្រាប់ថាពួកគាត់លែងជាប់បណ្ដឹងទៀតហើយ។ កត្តាទាំងនេះបានធ្វើឱ្យអ្នកស្រីរងផលប៉ះពាល់ផ្នែកស្មារតី ប៉ុន្តែមិនបញ្ឈប់អ្នកស្រីត្រឹមនោះទេ អ្នកស្រីបានគិតឡើងវិញយ៉ាងម៉ឺងមាត់ថា បើអ្នកស្រីឈប់ គឺមានន័យថាអ្នកស្រីបាក់ស្បាតដោយសារការគំរាមនេះ។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ អ្នកស្រីបានធ្វើការតស៊ូមតិដោយលើកឡើងពីច្បាប់ពាក់ព័ន្ធនាំអាជ្ញាធរចុះទៅកន្លែងកើតហេតុផ្ទាល់ និងផ្សព្វផ្សាយព័ត៌មានជាសាធារណៈ។

ដោយសារអ្នកស្រីជាអ្នកការពារសិទ្ធិជនជាតិដើមភាគតិច និងជាអ្នកការពារព្រៃឈើយ៉ាងសកម្ម ទើបនាំឱ្យសិទ្ធិសេរីភាពមួយចំនួនរបស់អ្នកស្រីត្រូវបានរឹតត្បិតជាងជនសាមញ្ញធម្មតា ដូចជា ការតាមឃ្លាំមើល និងតាមដាននៅពេលដែលអ្នកស្រីប្រមូលផ្ដុំធ្វើសកម្មភាពប្រជុំក្រុមការងារ និងប្រជុំចម្រៀងជនជាតិដើមភាគតិច បើទោះជាមិនតម្រូវឱ្យមានការជូនដំណឹងក៏ដោយ។

ក្នុងនាមជាស្ត្រីការពារសិទ្ធិជនជាតិដើមភាគតិច អ្នកស្រីយល់ថា សមភាពយេនឌ័រ គឺជាការបំពេញគ្នាទៅវិញទៅមក ទោះបីយើងដឹងថាស្ត្រី និងបុរសអាចមានសិទ្ធិស្មើគ្នា ប៉ុន្តែពេលខ្លះបុរសយល់ច្រឡំ ស្មើភាពគ្នាហ្នឹង គឺស្ត្រីត្រូវធ្វើការងារធ្ងន់ៗឱ្យដូចបុរស ប៉ុន្តែផ្ទុយមកវិញសមភាពយេនឌ័រគឺការបំពេញនៅអ្វីដែលខ្វះខាតដែលស្ត្រីធ្វើមិនបាន បុរសអាចជួយបំពេញ ហើយបុរសធ្វើមិនបាន ស្ត្រីអាចជួយបំពេញ។

អ្នកស្រីសំណូមពរ ឱ្យរដ្ឋាភិបាលគួរតែបើកឱកាសឱ្យស្ត្រីចូលរួមឱ្យបានជាក់ស្ដែង ជាពិសេស (ស្ត្រីជនជាតិភាគតិច) ជាជាងការសរសេរលើកទឹកចិត្តតែលើក្រដាស ដោយសារតែអាជ្ញាធរខេត្តមួយចំនួននៅតែមានការរើសអើងដល់ពួកគាត់ដែលជាស្ត្រីជនជាតិដើមភាគតិចដោយប្រើពាក្យអសុរោះនៅឡើយ៕

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

BY NC SA

ខែធ្នូ ឆ្នាំ២០១៩